**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ស្ពឺ**

**ក្រុមលទ្ធកម្ម**

លេខ : ....០១.......សជណ/.

# សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃការងារជួសជុលអគារកីឡា ទំហំ៥៥ម×៨០ម អគារការិយាល័យអប់រំស្រុកគងពិសីទំហំ៩ម×១៥ម និង របងទីលានកីឡាវត្តកំប៉ុតប្រវែង២២០ម ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ ឆ្នាំ២០១៦

មន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ស្ពឺ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហ-គ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ **ការងារជួសជុលអគារកីឡាទំហំ៥៥ម×៨០ម អគារការិយាល័យអប់រំស្រុកគងពិសី ទំហំ៩ម×១៥ម និងរបងទីលានកីឡាវត្តកំប៉ុតប្រវែង២២០ម ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ ឆ្នាំ២០១៦** ។

មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ស្ពឺ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅក្រុមលទ្ធកម្មមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ស្ពឺ ដែលមានអាសយដ្ឋាននៅក្នុងបរិវេណមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ស្ពឺ ចាប់ពីថ្ងៃទី ....១២.. ខែតុលា... ឆ្នាំ ២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទាក់ទងលេខ: ០២៥ ២១០ ២៧៨) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី...១០.......... ខែវិច្ឆិកា..........ឆ្នាំ២០១៦ វេលាម៉ោង...៩:០០......... ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ៩:០០.....ថ្ងៃទី១០. ខែវិច្ឆិកា..ឆ្នាំ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅ កំពង់ស្ពឺ ថ្ងៃទី...២៧.....ខែ...កញ្ញា.......ឆ្នាំ២០១៦

**ប្រធានក្រុមលទ្ធកម្ម**

**ស៊ិន_សុខា**

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-ក្រសួងអប់រំ យុវជន និងកីឡា

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ